ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដាក់ជនជាប់ចោទ អៀង ធីរិទ្ធ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្គាប់នូវរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រជារៀងរាល់ប្រាំមួយខែម្តង និងការត្រួតពិនិត្យប្រចាំខែដោយនគរបាលយុត្តិធម៌ ដោយស្របទៅតាមសេចក្តីសម្រេចរបស់ខ្លួនដែលបានចេញនៅថ្ងៃទី ១៤ ខែ ធ្នូ នេះ។

អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចទទួលយកបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាដោយផ្នែក ហើយបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៣ ខែ កញ្ញា ត្រង់ចំណុចដែលថា ក្នុង អំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានកំណត់ពេលលើជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូង មិនអាចអនុវត្តយុត្តាធិការលើជនជាប់ចោទបាន ហើយនិងខ្វះនូវមូលដ្ឋានផ្លូវច្បាប់ក្នុងការសម្រេចដាក់លក្ខខណ្ឌដោយបង្ខំលើការដោះលែងជនជាប់ចោទ។

នៅក្នុងពេលបច្ចុប្បន្ននេះ ជនជាប់ចោទ អៀង ធីរិទ្ធ មានកាតព្វកិច្ចជូនដំណឹងដល់ អ.វ.ត.ក នូវការផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលការពិនិត្យព្យាបាលផ្នែកវេជ្ជសាស្ត្រជារៀងរាល់ប្រាំមួយខែម្តងដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ផងដែរថា នគរបាលយុត្តិធម៌ ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំខែ ដើម្បីបញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបន្តស្នាក់នៅ អាសយដ្ឋានដដែលនេះ និងរាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចបដិសេធផ្នែកផ្សេងៗទៀតនៃបណ្តឹងសាទុក្ខ និងបានសម្រេចប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទៅឱ្យជនជាប់ចោទវិញ។

ជនជាប់ចោទអៀង ធីរិទ្ធ ដែលជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរងការចោទប្រកាន់ នៅខែ កញ្ញា ឆ្នាំ ២០១០ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទរំលោភដ៏ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងបទប្រល័យពូជសាសន៍។ ជនជាប់ចោទត្រូវបានរកឃើញថា ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដោយសារមានជំងឺវង្វេងវង្វាន់ កាលពីខែ វិច្ឆិកា ឆ្នាំ ២០១១ ហើយ កិច្ចដំណើរការនីតិវិធីជំនុំជម្រះលើរូបគាត់ ត្រូវបានផ្អាកចាប់ពីពេលនោះមក។ នៅខែ កញ្ញាក្នុងឆ្នាំនេះ អង្គជំនុំជម្រះសាលាដំបូង បានតម្កល់សារជាថ្មីនូវការយល់ឃើញរបស់ខ្លួនពីដំបូង ថាជនជាប់ចោទពុំមានសម្បទាចូលរួមសវនាការឡើយ ហើយបានបង្គាប់ដោះលែងដោយឥតលក្ខខណ្ឌ។ សហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចនេះ ដោយបានលើកឡើងថា ជាការចាំបាច់ដែល តម្រូវឱ្យមានការអនុវត្តនូវវិធានការមួយចំនួន ដើម្បីធានានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី សុវត្ថិភាពរបស់

ជនជាប់ចោទ និងសណ្តាប់ធ្នាប់សាធារណៈ។ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ នៅថ្ងៃទី ១៦ ខែ កញ្ញា ប្រធានអង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ឱ្យដោះលែងជនជាប់ចោទ ដោយតម្រូវឱ្យគោរពនូវលក្ខខណ្ឌមួយចំនួន។ ចាប់តាំងពីពេលនោះមក ជនជាប់ចោទស្ថិតក្រោមអ្នកអាណាព្យាបាលដែលជាកូនស្រីរបស់ខ្លួន គឺ លោកស្រី អៀង វិជីដា។

សូមអានសេចក្តីសម្រេចនេះ http://www.eccc.gov.kh/en/node/25220

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុផ្ទាល់ៈ +៨៥៥ (0) ២៣ ៨៦១ ៦៣៩
សារអេឡិកត្រូនិកៈ maeday@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh